**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.[illegible]

# ប្រកាស
# ស្តីពី
# ពន្ធលើមធ្យោបាយដឹកជញ្ជូន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ ស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

# សម្រេច

**ប្រការ១ .–**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន។

**ប្រការ២ .–**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .–**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- មធ្យោបាយដឹកជញ្ជូន សំដៅដល់ មធ្យោបាយដឹកជញ្ជូនឬយានជំនិះគ្រប់ប្រភេទមានជាអាទិ៍ កប៉ាល់ សាឡង់ ទូក កាណូត អូប័រ រថយន្ត ក្បាលរថយន្តសណ្តោង រ៉ឺម៉កសណ្តោង ស៊ីមីរ៉ឺម៉កសណ្តោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល។

២- ក្បាលរថយន្តសណ្តោង សំដៅដល់ រថយន្តសម្រាប់សណ្តោងស៊ីមីរ៉ឺម៉កសណ្តោង។

៣- ស៊ីមីរ៉ឺម៉កសណ្តោង សំដៅដល់ យានសម្រាប់ថ្ពក់ជាប់នឹងក្បាលរថយន្តសណ្តោង។

**ប្រការ៤ .–**

ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវបានកំណត់តាមអត្រាដូចខាងក្រោម៖

១-មធ្យោបាយដឹកជញ្ជូនទូទៅ៖

| ល.រ | ប្រភេទមធ្យោបាយដឹកជញ្ជូន | កម្រិតប្រាក់ពន្ធ សម្រាប់ ១ឆ្នាំ/គ្រឿង (គិតជារៀល) |
|---|---|---|
| ក | រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស)]៖ | |
| | - ដល់ ៣តោន | ២០០ ០០០ |
| | - លើសពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| | - លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| | - លើសពី ២០តោន ឡើងទៅ | ២ ០០០ ០០០ |
| ខ | ក្បាលរថយន្តសណ្តោងរួម និងស៊ីមីរ៉ឺម៉កសណ្តោង៖ | ២ ០០០ ០០០ |
| គ | រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (ទម្ងន់រ៉ឺម៉កនិងទម្ងន់ផ្ទុក)៖ | |
| | - ចាប់ពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| | - លើសពី១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| | - លើសពី ២០តោន ឡើងទៅ | ២ ០០០ ០០០ |

| | | | |
|---|---|---|---|
| ឃ | ជលយានឬជលយានយន្តផ្លូវទន្លេ៖ | | |
| | - ជលយានឬជលយានយន្តដឹកទំនិញ៖ | | |
| | | +ដល់ ៣តោន | ៥០ ០០០ |
| | | +លើសពី ៣តោន ដល់ ១០តោន | ១០០ ០០០ |
| | | +លើសពី ១០តោន ដល់ ២០តោន | ២០០ ០០០ |
| | | +លើសពី ២០តោន ឡើងទៅ | ៣០០ ០០០ |
| | - ជលយានឬជលយានយន្តដឹកអ្នកដំណើរ៖ | | |
| | | +កប៉ាល់មានបណ្តោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| | | +កប៉ាល់មានបណ្តោយលើសពី ២០ម៉ែត្រ ដល់ ៣០ម៉ែត្រ | ២០០ ០០០ |
| | | +កប៉ាល់មានបណ្តោយលើសពី ៣០ម៉ែត្រ ឡើងទៅ | ៣០០ ០០០ |
| | - ជលយានឬជលយានយន្តសណ្តោង៖ | | |
| | | +កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០ ០០០ |
| | | +កប៉ាល់មានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០ ០០០ |
| | | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ៣០០ ០០០ |
| | - ជលយានឬជលយានយន្តនេសាទ៖ | | |
| | | +កាណូតមានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០ ០០០ |
| | | +កាណូតមានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០ ០០០ |
| | | +កាណូតមានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ៣០០ ០០០ |
| ង | ជលយានឬជលយានយន្តផ្លូវសមុទ្រ៖ | | |
| | - ជលយានឬជលយានយន្តដឹកអ្នកដំណើរ៖ | | |
| | | +ទូកមានបណ្តោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| | | +ទូកមានបណ្តោយលើសពី ២០ម៉ែត្រ ឡើងទៅ | ១៥០ ០០០ |
| | - ជលយានឬជលយានយន្តដឹកទំនិញ៖ | | |
| | | +ទូកផ្ទុកទំនិញដល់ ១០០តោន | ២០០ ០០០ |
| | | +កប៉ាល់ផ្ទុកទំនិញលើសពី ១០០តោន ដល់ ១ ០០០តោន | ៣០០ ០០០ |
| | | +កប៉ាល់ផ្ទុកទំនិញលើសពី ១ ០០០តោន ដល់ ២ ០០០តោន | ៧៥០ ០០០ |
| | | +កប៉ាល់ផ្ទុកទំនិញលើសពី ២ ០០០តោន ឡើងទៅ | ១ ២០០ ០០០ |

| | | |
|---|---|---|
| | - ជលយានឬជលយានយន្តនេសាទ៖ | |
| | +ទូកមានកម្លាំងលើសពី ១៥០សេះ ឡើងទៅ | ១០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២៥០សេះ | ៤០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៦០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ១ ២០០ ០០០ |
| | - ជលយានឬជលយានយន្តសណ្តោង៖ | |
| | +កប៉ាល់មានកម្លាំងដល់ ២៥០សេះ | ២០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៤០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ៦០០ ០០០ |
| ច | អូប័រផ្លូវទន្លេឬសមុទ្រ៖ | |
| | - មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៤០០ ០០០ |
| | - មានកម្លាំងលើសពី ២០០សេះ ឡើងទៅ | ៥០០ ០០០ |

២-មធ្យោបាយដឹកជញ្ជូនកែច្នៃ៖

| ល.រ | ប្រភេទមធ្យោបាយដឹកជញ្ជូន | កម្រិតប្រាក់ពន្ធ សម្រាប់ ១ឆ្នាំ/គ្រឿង (គិតជារៀល) |
|---|---|---|
| ក | រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ | ២០០ ០០០ |
| ខ | រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ | ៥០០ ០០០ |
| គ | រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ | ១ ០០០ ០០០ |
| ឃ | រថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ | ២ ០០០ ០០០ |

៣-រថយន្តទេសចរណ៍៖

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម³ | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | ដល់ ៥ឆ្នាំ (គិតជារៀល) | លើសពី ៥ឆ្នាំដល់ ១០ឆ្នាំ (គិតជារៀល) | លើសពី ១០ឆ្នាំ (គិតជារៀល) |
| ក | ដល់ ១ ៥០០ស.ម³ | ១៥០ ០០០ | ១០០ ០០០ | ៨០ ០០០ |
| ខ | លើសពី ១ ៥០០ស.ម³ ដល់ ២ ០០០ស.ម³ | ២០០ ០០០ | ១៥០ ០០០ | ១០០ ០០០ |
| គ | លើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ស.ម³ | ៦០០ ០០០ | ៤០០ ០០០ | ២៥០ ០០០ |
| ឃ | លើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ស.ម³ | ១ ៦០០ ០០០ | ១ ០០០ ០០០ | ៦០០ ០០០ |
| ង | លើសពី ៤ ០០០ស.ម³ ឡើងទៅ | ២ ០០០ ០០០ | ១ ២០០ ០០០ | ៨០០ ០០០ |

៤- រថយន្តដឹកទំនិញធុនតូចមានទ្វារ ៤ (ភិកអាប់) ៖

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម^៣ | គិតពីឆ្នាំផលិត | |
|---|---|---|---|
| | | **ដល់ ៥ឆ្នាំ** (គិតជារៀល) | **លើសពី ៥ឆ្នាំ** (គិតជារៀល) |
| ក | ដល់ ១ ៥០០ស.ម^៣ | ១៥០ ០០០ | ១០០ ០០០ |
| ខ | លើសពី ១ ៥០០ស.ម^៣ ដល់ ២ ០០០ស.ម^៣ | ២០០ ០០០ | ១៥០ ០០០ |
| គ | លើសពី ២ ០០០ស.ម^៣ ដល់ ២ ៩០០ស.ម^៣ | ៦០០ ០០០ | ២០០ ០០០ |
| ឃ | លើសពី ២ ៩០០ស.ម^៣ ដល់ ៤ ០០០ស.ម^៣ | ១ ៦០០ ០០០ | ២០០ ០០០ |
| ង | លើសពី ៤ ០០០ស.ម^៣ ឡើងទៅ | ២ ០០០ ០០០ | ២០០ ០០០ |

៥- រថយន្តដឹកអ្នកដំណើរ៖

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម^៣ | គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ (គិតជារៀល) |
|---|---|---|
| ក | ដល់ ១ ៥០០ស.ម^៣ | ១៥០ ០០០ |
| ខ | លើសពី ១ ៥០០ស.ម^៣ ដល់ ២ ០០០ស.ម^៣ | ២០០ ០០០ |
| គ | លើសពី ២ ០០០ស.ម^៣ ដល់ ២ ៩០០ស.ម^៣ | ៦០០ ០០០ |
| ឃ | លើសពី ២ ៩០០ស.ម^៣ ដល់ ៤ ០០០ស.ម^៣ | ១ ៦០០ ០០០ |
| ង | លើសពី ៤ ០០០ស.ម^៣ ឡើងទៅ | ២ ០០០ ០០០ |
| | **ចំនួនកៅអី** | **គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ** (គិតជារៀល) |
| ច | រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | ១៥០ ០០០ |
| ឆ | រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥កៅអី | ២០០ ០០០ |
| ជ | រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥កៅអី ឡើងទៅ | ២៥០ ០០០ |

៦- រថយន្តប្រើប្រាស់ថាមពលអគ្គិសនី (អ៊ីវី) ប្រភេទទេសចរណ៍ រថយន្តដឹកទំនិញធុនតូចមានទ្វារ ៤ (ភិកអាប់) និងរថយន្តដឹកអ្នកដំណើរ៖

| ល.រ | គិតជាកម្លាំងសេះ | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | **ដល់ ៥ឆ្នាំ** (គិតជារៀល) | **លើសពី ៥ឆ្នាំដល់ ១០ឆ្នាំ** (គិតជារៀល) | **លើសពី ១០ឆ្នាំ** (គិតជារៀល) |
| ក | ដល់ ១៥០សេះ | ១០០ ០០០ | ៨០ ០០០ | ៦០ ០០០ |
| ខ | លើសពី ១៥០សេះ ដល់ ២០០សេះ | ១៥០ ០០០ | ១០០ ០០០ | ៨០ ០០០ |
| គ | លើសពី ២០០សេះ ដល់ ២៥០សេះ | ៥០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ |
| ឃ | លើសពី ២៥០សេះ ដល់ ៣០០សេះ | ១ ២០០ ០០០ | ៨០០ ០០០ | ៤០០ ០០០ |
| ង | លើសពី ៣០០សេះ ឡើងទៅ | ១ ៦០០ ០០០ | ១ ០០០ ០០០ | ៦០០ ០០០ |

**ប្រការ៥ .-**

ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវបានលើកលែងដូចខាងក្រោម៖

១- រថយន្តគិលានសង្គ្រោះ និងរថយន្តពន្លត់អគ្គីភ័យជាកម្មសិទ្ធិរបស់រដ្ឋ។

២- យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើការងារសម្រាប់គោលដៅនៃការការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សង្គមតែប៉ុណ្ណោះ។

៣- យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូតឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

៤-រទោចក្រយានយន្តនិងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រនិងគ្រឿងយន្តប្រហាក់ប្រហែល និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ (មួយរយហាសិប) សេះ ឬតិចជាង។

៥- រថយន្តដែលបំប្លែងមកពីគោយន្ត និងរថយន្តកែច្នៃកង់បីដែលបំពាក់ម៉ាស៊ីន។

**ប្រការ៦ .-**

១- ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវអនុវត្តចំពោះម្ចាស់កម្មសិទ្ធិនៃមធ្យោបាយដឹកជញ្ជូន។

២- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាង ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមិថុនា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ។

៣- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាង ត្រូវបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូននៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត ខណ្ឌ ឬធនាគារជាដៃគូ ឬតាមរយៈកម្មវិធីទូរស័ព្ទដៃ។

**ប្រការ៧ .-**

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវអនុវត្តដូចខាងក្រោម៖

១- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាង ត្រូវមកចុះបញ្ជីនិងដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើកដំបូង ដោយត្រូវបំពេញព័ត៌មានទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ និងត្រូវមានឯកសារ ដូចខាងក្រោម៖

ក- រថយន្តទេសចរណ៍៖

- ច្បាប់ដើមនៃបណ្ណសម្គាល់យានជំនិះ និង
- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតឆ្លងដែនរបស់ម្ចាស់កម្មសិទ្ធិ និង
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារចំពោះនីតិបុគ្គល។

ខ- រថយន្តដឹកទំនិញ ឬរថយន្តដឹកអ្នកដំណើរ ឬជលយានយន្ត៖

- ច្បាប់ដើមនៃបណ្ណសម្គាល់យានជំនិះ និង
- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតឆ្លងដែនរបស់ម្ចាស់កម្មសិទ្ធិ និង
- ច្បាប់ដើមនៃវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន និង
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារចំពោះនីតិបុគ្គល។

គ- យានយន្តកែច្នៃក្នុងស្រុក៖

- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតឆ្លងដែនរបស់ម្ចាស់កម្មសិទ្ធិ និង
- ច្បាប់ដើមនៃលិខិតបញ្ជាក់ការប្រើប្រាស់យានជំនិះចេញដោយឃុំ សង្កាត់ និង
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារចំពោះនីតិបុគ្គល។

២- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាង ដែលបានចុះបញ្ជីនិងប្រកាសនិងបង់ប្រាក់ពន្ធរួចម្តងមកហើយ ត្រូវមានឯកសារដូចខាងក្រោម៖

ក- បណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន ឬ

ខ- បណ្ណសម្គាល់យានជំនិះ ឬ

គ- បង្កាន់ដៃទទួលប្រាក់ពន្ធមធ្យោបាយដឹកជញ្ជូន ឬ

ឃ-លតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូនឆ្នាំចាស់។

៣- ចំពោះមធ្យោបាយដឹកជញ្ជូនដែលបានចុះបញ្ជីនិងបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធរួចហើយ ហើយត្រូវបានប្តូរបណ្ណសម្គាល់យានជំនិះដោយសារមានការផ្លាស់ប្តូរព័ត៌មាន ម្ចាស់មធ្យោបាយដឹកជញ្ជូនត្រូវស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានមធ្យោបាយដឹកជញ្ជូននោះនៅអគ្គនាយកដ្ឋានពន្ធដារ ឬនៅសាខាពន្ធដារខេត្ត ខណ្ឌ ដើម្បីប្រកាសបង់ពន្ធបន្តព្រមទាំងអាចប្តូរបណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូនផងដែរ។

៤- ក្រោយពេលបង់ពន្ធរួច ម្ចាស់មធ្យោបាយដឹកជញ្ជូនត្រូវទទួលបានបង្កាន់ដៃទទួលប្រាក់ពន្ធមធ្យោបាយដឹកជញ្ជូន និងលតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន។ លតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន ត្រូវបិទភ្ជាប់ជាមួយនឹងមធ្យោបាយដឹកជញ្ជូននោះ ហើយបង្កាន់ដៃទទួលប្រាក់ពន្ធ អាចរក្សាទុកសម្រាប់ប្រើប្រាស់តាមការចាំបាច់។

៥- ម្ចាស់មធ្យោបាយដឹកជញ្ជូន អាចស្នើសុំបណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងបង់ថ្លៃសេវាចំនួន ៥ ០០០ រៀល នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត ខណ្ឌ ឬនៅធនាគារដៃគូ។ បណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន មានទម្រង់ជាបណ្ណរឹង និងបណ្ណទម្រង់ឌីជីថល (E-CARD)។ បន្ទាប់ពីការបង់ប្រាក់ពន្ធនិងថ្លៃសេវា ម្ចាស់មធ្យោបាយដឹកជញ្ជូននឹងទទួលបានភ្លាមៗនូវបណ្ណរឹង ពីអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ខណ្ឌ ឬបណ្ណទម្រង់ឌីជីថល (E-CARD) តាមអនឡាញ។

៦- ករណីបាត់លតាបត្រ ម្ចាស់មធ្យោបាយដឹកជញ្ជូនអាចដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន នៅអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ខណ្ឌ ដើម្បីប្រើប្រាស់តាមការចាំបាច់។

**ប្រការ៨ ._**

ចំពោះមធ្យោបាយដឹកជញ្ជូនដែលជាកម្មសិទ្ធិរបស់ក្រសួង ស្ថាប័នរដ្ឋ ស្ថានទូត ស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ត្រូវបានកំណត់ដូចខាងក្រោម៖

១- មធ្យោបាយដឹកជញ្ជូនដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃប្រការ៥ នៃប្រកាសនេះ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបាននូវលតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន (លើកលែងពន្ធ) ដោយភ្ជាប់មកជាមួយនូវបញ្ជីសារពើភណ្ឌយានយន្តទ្រព្យសម្បត្តិរដ្ឋ (តារាងកើនឡើងនិងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ) ដែលចុះបញ្ជីនៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- មធ្យោបាយដឹកជញ្ជូនដែលជាកម្មសិទ្ធិរបស់ក្រសួង ស្ថាប័នរដ្ឋ (ពាក់ផ្លាកលេខរដ្ឋ) ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ខណ្ឌ ដើម្បីបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន ដោយភ្ជាប់មកជាមួយនូវលិខិតជូនដំណឹងឥណទានរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារខេត្ត និងបញ្ជីសារពើភណ្ឌយានយន្តទ្រព្យសម្បត្តិរដ្ឋ (តារាងកើនឡើងនិងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ) ដែលចុះបញ្ជីនៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៩ ._**

ចំពោះមធ្យោបាយដឹកជញ្ជូនទាំងឡាយណា ដែលមានបង្កាន់ដៃបង់ពន្ធនាំចូលចេញមុនខែធ្នូ តែមានបណ្ណសម្គាល់យានជំនិះចេញលើកដំបូងក្នុងខែធ្នូនៃឆ្នាំជាប់ពន្ធចរន្ត ត្រូវបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនក្នុងឆ្នាំនោះ ដោយទទួលបានការលើកលែងប្រាក់ពន្ធបន្ថែម។ ក្នុងករណីបណ្ណសម្គាល់យានជំនិះចេញលើកដំបូងក្នុងខែធ្នូ និងមានបង្កាន់ដៃបង់ពន្ធនាំចូលចេញក្នុងខែធ្នូឆ្នាំតែមួយ ត្រូវបានអនុញ្ញាតឱ្យបង់ពន្ធសម្រាប់ឆ្នាំបន្ទាប់។

**ប្រការ១០ .-**

ជារៀងរាល់ឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា នៃឆ្នាំបន្ទាប់ អគ្គនាយកដ្ឋានពន្ធដារត្រូវរៀបចំយន្តការត្រួតពិនិត្យការបង់ពន្ធ និងពន្ធបន្ថែមចំពោះមធ្យោបាយដឹកជញ្ជូនដែលមិនបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំ តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

**ប្រការ១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ